| | |
|---|---|
| លេខកម្ចី/ជំនួយឥតសំណង របស់ ADB និង ឈ្មោះគម្រោង៖ | |
| លេខកិច្ចសន្យា និង ការពណ៌នា៖ | |
| ឈ្មោះអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ/ទីប្រឹក្សា ៖ | |
| រៀបចំដោយ ៖ | |
| កាលបរិច្ឆេទ ៖ | |
| ត្រួតពិនិត្យឡើងវិញ/ឯកភាពដោយ ៖ | |
| កាលបរិច្ឆេទ ៖ | |

**សេចក្តីណែនាំ ៖**

*ទីភ្នាក់ងារប្រតិបត្តិ ទីភ្នាក់ងារអនុវត្ត អង្គភាពគ្រប់គ្រងគម្រោង អង្គភាពអនុវត្តគម្រោង គប្បីធានាថា មូលនិធិគម្រោងត្រូវបានប្រើប្រាស់ទៅតាមគោលដៅ។*

*បញ្ជីផ្ទៀងផ្ទាត់នេះ មានគោលបំណងកំណត់ថាតើ (១) មានឯកសារគ្រប់គ្រាន់សម្រាប់គាំទ្រការចំណាយដែរឬទេ (២) ការទូទាត់ប្រាក់សម្រាប់កិច្ចសន្យាមានភាពសុក្រឹត្យដែរឬទេ និងត្រូវបានទូទាត់ជូនភ្លាមៗស្របតាមលក្ខខណ្ឌនៃការទូទាត់ប្រាក់ដូចមានកំណត់ចែងនៅក្នុងកិច្ចសន្យាដែរទេ (៣) រាល់ការចម្លងទាំងអស់មានភាពពិតប្រាកដបានទទួលការអនុញ្ញាត និងមានការត្រួតពិនិត្យ និងអនុម័តត្រឹមត្រូវ និង (៤) រាល់ការចម្លងទាំងអស់មានលក្ខខណ្ឌសមស្របសម្រាប់ការផ្តល់ហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។*

*ប្រសើរបំផុត បញ្ជីផ្ទៀងផ្ទាត់នេះ គប្បីត្រូវបានបំពេញឱ្យបានទៀងទាត់សម្រាប់**កិច្ចសន្យានីមួយៗ** ដោយផ្អែកលើគំរូនៃចម្លងការ/ពាក្យសុំដកប្រាក់ ដែលធ្វើឡើងដោយបុគ្គលិកគម្រោងសំខាន់ៗរបស់ទីភ្នាក់ងារប្រតិបត្តិ ទីភ្នាក់ងារអនុវត្ត ឬ អង្គភាពគ្រប់គ្រងគម្រោង ជាពិសេស គឺពីក្រុមគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោង។*

## បញ្ជីផ្ទៀងផ្ទាត់ទី២ ៖ បញ្ជីផ្ទៀងផ្ទាត់អំពីការដកសាច់ប្រាក់របស់ទីភ្នាក់ងារប្រតិបត្តិ

| ល.រ | សំនួរ | Y | N | NA | កំណត់សម្គាល់/សម្រាប់ចំណាត់ការ |
|---|---|---|---|---|---|
| 1 | តើយើងរក្សាទុកនូវសៀវភៅ/កំណត់ហេតុត្រួតពិនិត្យសម្រាប់កិច្ចសន្យានីមួយៗដែរឬទេ? | | | | សូមបញ្ជាក់អំពីការដកសាច់ប្រាក់សរុបនៃកិច្ចសន្យានេះ គិតត្រឹមកាលបរិច្ឆេទនៃការត្រួតពិនិត្យឡើងវិញ។ |
| | • តើយើងធ្វើការទូទាត់ជាទៀងទាត់ទៅលើការដកសាច់ប្រាក់សរុបនៅក្នុងសៀវភៅកិច្ចសន្យាមួយ ជាមួយនឹងកំណត់ហេតុនៃការដកសាច់ប្រាក់សរុបរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ពី LFIS) និងម្ចាស់ជំនួយដទៃទៀត (ប្រសិនបើមានការផ្តល់មូលនិធិពីម្ចាស់ជំនួយដទៃទៀតក្រៅពីធនាគារអភិវឌ្ឍន៍អាស៊ី) ដែរឬទេ? | | | | សូមបញ្ជាក់អំពីភាពញឹកញាប់នៃការទូទាត់ចំពោះការដកសាច់ប្រាក់ក្នុងកិច្ចសន្យាជាមួយនឹងកំណត់ហេតុរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ |
| | • ចំពោះកិច្ចសន្យាដែលផ្តល់មូលនិធិគាំទ្រដោយពហុម្ចាស់ជំនួយ (ឧ. ADB, JICA, AusAid ។ល។) តើសៀវភៅគណនេយ្យ មានបានកំណត់អំពីចំនួនសាច់ប្រាក់ដែលបានដក សម្រាប់អង្គការ/ទីភ្នាក់ងារផ្តល់ជំនួយនីមួយៗដែរឬទេ? | | | | |
| 2 | *ត្រួតពិនិត្យឡើងវិញទៅលើពាក្យសុំដកប្រាក់ដែលបានជ្រើសរើស និង ឯកសារគាំទ្រការទូទាត់ប្រាក់សម្រាប់កិច្ចសន្យានេះ ដើម្បីធានាថាវឌ្ឍនភាព និងការទូទាត់ប្រាក់ចុងក្រោយ មានភាពសុក្រឹត្យ មានការគាំទ្រត្រឹមត្រូវ រាប់បញ្ចូលការទូទាត់សាច់ប្រាក់វឌ្ឍទ័យបុរេប្រទានឱ្យបានសមស្របផងដែរ។ បញ្ចូលការប្រើប្រាស់នីតិវិធី SOE។* | | | | |
| | • តើចំនួនសាច់ប្រាក់ត្រូវបានទូទាត់ជូនត្រឹមត្រូវទៅតាមកាលវិភាគទូទាត់ប្រាក់ដូចមានកំណត់នៅក្នុងកិច្ចសន្យាដែរឬទេ? | | | | ប្រសិនបើមិនបានត្រឹមត្រូវទេនោះ: សូមបញ្ជាក់អំពីលេខឯកសារសុំដកប្រាក់ រយៈពេលដែលខុសគ្នាពីកាលវិភាគទូទាត់ប្រាក់ដូចមានកំណត់នៅក្នុងកិច្ចសន្យា និងមូលហេតុដែលនាំឱ្យមានភាពខុសគ្នាបែបនេះ។ |
| | • សម្រាប់ការទូទាត់ប្រាក់ដែលត្រូវបានធ្វើឡើងមិនស្របតាមកាលវិភាគនៃការទូទាត់ប្រាក់ដូចមានកំណត់នៅក្នុងកិច្ចសន្យា តើការទូទាត់ប្រាក់ទាំងនោះមានការផ្តល់មូលហេតុ និងការឯកភាពសមស្របដែរឬទេ? | | | | សូមបញ្ជាក់អំពីមូលហេតុដែលបានផ្តល់ជូន និងឈ្មោះមន្ត្រីដែលផ្តល់ការឯកភាព។ |

## បញ្ជីផ្ទៀងផ្ទាត់ទី២ ៖ បញ្ជីផ្ទៀងផ្ទាត់អំពីការដកសាច់ប្រាក់របស់ទីភ្នាក់ងារប្រតិបត្តិ

| ល.រ | សំនួរ | Y | N | NA | កំណត់សម្គាល់/សម្រាប់ចំណាត់ការ |
|---|---|---|---|---|---|
| | • តើឯកសារគាំទ្រដល់ការដកសាច់ប្រាក់ ដូចជាវិក្កយប័ត្រ បង្កាន់ដៃទទួលប្រាក់ លិខិតបញ្ជាក់អំពីការទូទាត់ប្រាក់ ផ្ទៀបនឹងវឌ្ឍនភាពដែលសម្រេចបាន និងលិខិតបញ្ជាក់អំពីការទទួលយក (សម្រាប់ការទូទាត់ប្រាក់លើកចុងក្រោយ) មានលក្ខណៈគ្រប់ជ្រុងជ្រោយដែរឬទេ?<br><br>*ឧទាហរណ៍នៃឯកសារគាំទ្រដែលជាការរំពឹងទុករបស់អ្នក រួមមានដូចតទៅ ៖ លិខិតបញ្ជាក់អំពីការចុះត្រួតពិនិត្យ វិក្កយប័ត្រ/បង្កាន់ដៃទទួលប្រាក់សម្រាប់អ្នកផ្គត់ផ្គង់សម្ភារៈការិយាល័យ ឯកសារតារាងពេលវេលារបស់ទីប្រឹក្សា ភស្តុតាងបញ្ជាក់អំពីការប្រគល់ទំនិញ។* | | | | ប្រសិនបើពុំមានលក្ខណៈគ្រប់ជ្រុងជ្រោយទេនោះ សូមបញ្ជាក់អំពីលេខពាក្យសុំដកប្រាក់ សេចក្តីពណ៌នាអំពីការទូទាត់ប្រាក់ដែលពុំមានឯកសារគាំទ្រគ្រប់គ្រាន់ ប្រភេទឯកសារគាំទ្រដែលមិនគ្រប់គ្រាន់។ |
| | • សម្រាប់ការទូទាត់ប្រាក់ដែលត្រូវបានធ្វើឡើងដោយពុំមានការឯកសារគាំទ្រគ្រប់គ្រាន់ តើការទូទាត់ប្រាក់ទាំងនោះមានការផ្តល់មូលហេតុ និងការឯកភាពសមស្របដែរឬទេ? | | | | សូមបញ្ជាក់អំពីមូលហេតុដែលបានផ្តល់ជូន និងឈ្មោះមន្ត្រីដែលផ្តល់ការឯកភាព។ |
| | • តើមានឯកសារគាំទ្រដែល "ខុសប្រក្រតី" ដូចជា ៖<br>○ មានការកោសលុប និង/ឬ កែតម្រូវ? | | | | ទាំងនេះគឺជា "សញ្ញាត្រូវប្រុងប្រយ័ត្ន" ជាសក្តានុពល។ ប្រសិនបើអ្នកកត់សម្គាល់ឃើញមានសញ្ញាណាមួយក្នុងចំណោមសញ្ញាទាំងនេះ សូមរាយការណ៍ រួមជាមួយនឹងឯកសារចម្លងមួយច្បាប់ ដាក់ជូនទៅការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាពនៃធនាគារអភិវឌ្ឍន៍អាស៊ី។ |
| | ○ គ្មានទម្រង់លិខិតក្រុមហ៊ុន/ទម្រង់លិខិតក្រុមហ៊ុនមិនប្រក្រតី? | | | | |
| | ○ ការទិញដដែលៗ ដែលហាក់បីដូចជាមិនសមហេតុផល? | | | | |
| | ○ ការទិញដែលមិនស្របទៅនឹងកិច្ចសន្យា ឬ មិនសមហេតុផល? | | | | |
| | ○ បាត់ឯកសារ ឬ ឯកសារត្រូវបានផ្លាស់ប្តូរ? | | | | |

## បញ្ជីផ្ទៀងផ្ទាត់ទី២ ៖ បញ្ជីផ្ទៀងផ្ទាត់អំពីការដកសាច់ប្រាក់របស់ទីន្នាក់ងារប្រតិបត្តិ

| ល.រ | សំនួរ | Y | N | NA | កំណត់សម្គាល់/សម្រាប់ចំណាត់ការ |
|---|---|---|---|---|---|
| | ○ ឯកសារថតចម្លងជំនួសឱ្យឯកសារគាំទ្រច្បាប់ដើម? | | | | |
| | ○ វិក្កយប័ត្រ ឬ បង្កាន់ដៃទទួលប្រាក់ផ្លូវការដែលមានភាពខុសគ្នាពីវិក្កយប័ត្រ ឬ បង្កាន់ដៃទទួលប្រាក់ដទៃទៀត? | | | | |
| | • តើបុគ្គលដែលមានសិទ្ធិអំណាចផ្តល់ការអនុម័តនៅក្នុងពាក្យសុំដកប្រាក់ មានភាពអនុលោមស្របតាមការកំណត់ដែរឬទេ? | | | | ប្រសិនបើពុំមានភាពស្របតាមការកំណត់ទេនោះ សូមបញ្ជាក់អំពីបុគ្គលដែលពុំមានភាពអនុលោម។ |
| | • សម្រាប់ *ការងារសំណង់ស៊ីវិល* តើលិខិតបញ្ជាក់អំពីវឌ្ឍនភាព/ការសម្រេចការងារត្រូវបានចុះហត្ថលេខាសមស្រប ដោយវិស្វករដែលត្រូវបានតែងតាំងឱ្យបញ្ជាក់ថាការងារត្រូវបានត្រួតពិនិត្យរួចរាល់មុនពេលទូទាត់ប្រាក់ជូន ដែរឬទេ? | | | | សូមបញ្ជាក់អំពីវិស្វករដែលត្រូវបានប្រគល់សិទ្ធិជូនដើម្បីចុះហត្ថលេខាទៅលើរបាយការណ៍ស្តីពីវឌ្ឍនភាព/របាយការណ៍បញ្ចប់ ឬ របាយការណ៍ត្រួតពិនិត្យ។<br>ប្រសិនបើពុំមានការចុះហត្ថលេខាទេនោះ សូមបញ្ជាក់អំពីហេតុផល។ |
| | • សម្រាប់ *កិច្ចសន្យាផ្តល់សេវាទីប្រឹក្សា* តើមានឯកសារបញ្ជាក់ថា លទ្ធផលការងាររបស់ទីប្រឹក្សាត្រូវបានផ្តល់ជូន និងទទួលយក ដើម្បីគាំទ្រដល់ការទូទាត់ប្រាក់ដែលត្រូវបានធ្វើឡើង និងសម្រាប់គោលបំណងដទៃទៀត ដែរឬទេ? | | | | ប្រសិនបើពុំមានទេនោះ សូមបញ្ជាក់អំពីមូលហេតុ។ |
| | • សម្រាប់ *កិច្ចសន្យាផ្តល់សេវាទីប្រឹក្សា* តើការទាមទារទូទាត់ប្រាក់របស់ទីប្រឹក្សាដែលត្រូវបានទូទាត់ជូន មានលក្ខខណ្ឌសមស្រប និង មានឯកសារគាំទ្រសមស្រប ដែរឬទេ (ឧ. ឯកសារតារាងពេលវេលាដែលចុះហត្ថលេខាដោយទីប្រឹក្សា)? | | | | ប្រសិនបើពុំមានទេនោះ សូមបញ្ជាក់អំពីការទូទាត់ប្រាក់ដែលត្រូវបានធ្វើឡើងចំពោះការទាមទារទូទាត់ប្រាក់ ដែលពុំមានលក្ខខណ្ឌសមស្រប និងឯកសារគាំទ្រគ្រប់គ្រាន់។ |
| | • សម្រាប់ *កិច្ចសន្យាផ្គត់ផ្គង់ទំនិញ* តើទំនិញដែលត្រូវបានផ្តល់ជូន មានការត្រួតពិនិត្យមុនពេលទទួលយក និងទូទាត់ប្រាក់ដែរទេ? | | | | |

## បញ្ជីផ្ទៀងផ្ទាត់ទី២ ៖ បញ្ជីផ្ទៀងផ្ទាត់អំពីការដកសាច់ប្រាក់របស់ទីភ្នាក់ងារប្រតិបត្តិ

| ល.រ | សំនួរ | Y | N | NA | កំណត់សម្គាល់/សម្រាប់ចំណាត់ការ |
|---|---|---|---|---|---|
| | • សម្រាប់ ***កិច្ចសន្យាផ្គត់ផ្គង់ទំនិញ*** តើការទូទាត់ប្រាក់ ស្ថិតក្រោមការគ្រប់ដណ្ដប់នៃរបាយការណ៍ត្រួតពិនិត្យ ដែរឬទេ? | | | | សូមបញ្ជាក់ថាតើនរណាជាអ្នកពិនិត្យទៅលើទំនិញដែលត្រូវបានប្រគល់ជូន និងបញ្ជាក់ទៅលើការទទួលយកទំនិញ។<br><br>ក្នុងករណីដែលអាចមានទំនាស់ផលប្រយោជន៍ សូមបញ្ជាក់នៅត្រង់នេះ និងផ្លាស់ប្តូរសមាជិកក្រុមត្រួតពិនិត្យ។ ចូរកត់ត្រាអំពីការផ្លាស់ប្តូរបែបនេះ។ |
| | ○ ផ្អែកលើរបាយការណ៍ត្រួតពិនិត្យ តើអាចមានទំនាស់ផលប្រយោជន៍ចំពោះសមាជិកនៃក្រុម/បុគ្គលិកត្រួតពិនិត្យ ដែរឬទេ? | | | | |